( ចំណាយដំណើរការរដ្ឋបាល និង ... ) ក្នុងរង្វង់ថវិការបស់ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៧។

**មាត្រា ២** : ឥណទានក្នុងមាត្រា១ ត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ទូទាត់ ... គយ និង ពន្ធដារ និងបន្ថែមចំណាយដំណើរការរដ្ឋបាល សំភារៈ ។

**មាត្រា ៣** : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

* * *

## អនុក្រឹត្យលេខ : ៣០ អនក្រ.បក

## ស្តីពីការរៀបចំដំណើរការឡើងវិញ នូវក្រុម ហ៊ុន

## អាកាសចរកម្ពុជា

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រឹត្រលេខ ១០៩៤.៩០នស/រកត ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

- បានឃើញសេចក្ដីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ២៨ សសរ ចុះថ្ងៃទី ០២ ខែ ឧសភា ស្ដីពីការបង្កើតក្រុមហ៊ុនអាកាសចរកម្ពុជា
- តាមសំណូមពរការងារចាំបាច់

សំរេច

មាត្រា ១ : រៀបចំអោយមានការដំណើរការឡើងវិញនូវក្រុមហ៊ុនអាកាសចរកម្ពុជា (KAMPUCHEA AIRLINE) អក្សរកាត់ (KAL) ។

មាត្រា ២ : ក្រុមហ៊ុនអាកាសចរកម្ពុជា ស្ថិតនៅក្រោមការដឹកនាំរបស់ប្រធានមួយរូប និងនាយករង ជាជំនួយការ ។

មាត្រា ៣ : អនុញ្ញាតជាគោលការណ៍ អោយក្រុមហ៊ុនអាកាសចរកម្ពុជា ធ្វើសហការជាមួយក្រុមហ៊ុន ORIENT THAI AIRLINES ក្នុងការធ្វើអាជីវកម្មដឹកជញ្ជូនតាមផ្លូវអាកាស តាមការកំណត់ដែលមានចែងក្នុងកិច្ចសន្យា រវាងក្រុមហ៊ុនទាំងពីរ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលកម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង ក្រុមហ៊ុនអាកាសចរកម្ពុជា ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

* * *

## អនុក្រឹត្យលេខ : ៣៦ អនក្រ.បក

## ស្ដីពីការបង្កើត ថ្នាក់ពីរកងពលធំថ្មើរជើង ពីរកងពលតូចថ្មើរជើង និង មួយកងពលតូចវិស្វកម្ម

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា